រុក្ខជាតិដែលងាយរងគ្រោះថ្នាក់នៅដែនដីខាងជើង

សហគមន៍រុក្ខជាតិលើកំរាលខ្សាច

តើសហគមន៍រុក្ខជាតិលើកំរាលខ្សាច់អ្វី?

កំរាលខ្សាច់មានដីគ្មានជីជាតិដែលមានជាតិអាស៊ីតគ្របពីលើពំនូកដីឥដ្ឋឬថ្មបាយក្រៀមដែលមិនជ្រាបទឹក ហើយលិចទឹកក្នុងរដូវភ្លៀង។

ហាស្សេស(Heath) គឺជាពាក្យដែលគេប្រើដើម្បីពិពណ៌នាសហគមន៍រុក្ខជាតិដែលគេរកឃើញនៅលើ កំរាលខ្សាច់។

សហគមន៍រុក្ខជាតិលើកំរាលខ្សាច់មានសំណុំភាវៈរស់ចំរុះដែលជាធម្មតាមានតិណទសេ(herbs)និង អិជ(edges) ជាច្រើនប្រភេទនៅស្រទាប់ខាងក្រោមហើយនៅស្រទាប់លើមានដើមឈើតូចៗឬចុល្លព្រឹក្សសម្រាប់លំអដូចជា Grevillea pteridifolia Banksia dentata, Verticordia cunninghamii នឹង Melaleuca nervosa។

ដំបន់ដីសើមដែលឆ្អែតទឹកទៅតាមរដូវទាំងនេះជាទីជំរករស់នៅដ៏សំខាន់សំរាប់សឹងតែគ្រប់សំណុំភាវៈរស់ស៊ីសាច់ទាំងអស់(តិណទសេដែលស៊ីសាច់ជាអាហារ)ដែលគេប្រទះឃើញនៅតំបន់ដាវីន។

សហគមន៍រុក្ខជាតិលើកំរាលខ្សាច់ច្រើនតែទាក់ទងនឹងព្រៃរង់ទឹកភ្លៀងមូស្សុង តំបន់ដីសើមផ្សេងទៀតរុក្ខជាតិតាមមាត់ទន្លេឬអូរ។ ទាំងនេះគឺជាប្រភេទរុក្ខជាតិដែលត្រូវបានរឹតត្បិតនៅដែនដីភាគខាងជើងនិងតំបន់ចំណុចក្តៅសំរាប់ជីវចំរុះ។

ហេតុអ្វីបានជាសហគមន៍រុក្ខជាតិលើកំរាលខ្សាច់មានសារៈសំខាន់?

សហគមន៍រុក្ខជាតិលើកំរាលខ្សាច់គឺជាប្រភេទរុក្ខជាតិដ៏កម្រដែលមានវត្តមាននៅតំបន់ដាវីនហើយគ្របដណ្តប់លើផ្ទៃដី ៥៦គីឡូម៉ែតការេ។ ទោះបីជាវាមិនត្រូវបានគេចុះបញ្ជីជាផ្លូវការថាជាប្រភេទដែលទទួលរងការគំរាមកំហែងក៏ដោយ ក៏សហគមន៍រុក្ខជាតិលើកំរាលខ្សាច់ដែលឆ្អែតទឹកទៅតាម រដូវ(seasonallysaturated sandsheets)ដែលទ្រទ្រង់តំបន់គ្របដណ្តប់ដោយរុក្ខជាតិឬតំបន់ដីសើម តិណទសេ(wet herbfield)ត្រូវបានគេរឹតត្បិត និងទទួលស្គាល់ថាជាប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ដាវីនដែលប្រឈមមុខរងគ្រោះ។

សំណុំភាវៈរស់រុក្ខជាតិ និងសត្វជាច្រើនបានសន្សឹមខ្លួនហើយពួកវាភាគច្រើនឬទាំងស្រុងស្ថិតនៅតែក្នុងប្រភេទជំរករស់នៅនេះទម្លួមទាំង Howard River Toadlet (Uperoleia daviesae)។

Howard River Toadlet ត្រូវបានគេរកឃើញនៅឆ្នាំ ២០០០ ហើយទោះបីជាគេដឹងតិចតួចពីសំណុំភាវៈរស់នេះក៏ដោយ វាហាក់បីដូចជាដុះនៅតែលើរាបមានខ្សាច់ដែលលិចទឹកតាមរដូវ។ Toadlet គឺជាកង្កែបនៅដែនដីភាគខាងជើងតែមួយប៉ុណ្ណោះដែលត្រូវបានចុះបញ្ជីជាប្រភេទដែលទទួលរងការគំរាមកំហែង។

ប្រភេទស៊ីសាច់

ប្រភេទស៊ីសាច់(genus Utricularia)គឺជាក្រុមដ៏អស្ចារ្យមួយនៃរុក្ខជាតិតូចៗស៊ីសាច់ដែលមានអង្គប់ពិសេសសំរាប់ចាប់និងរំលាយសត្វល្អិតជាអាហារ។រុក្ខជាតិទាំងនេះបន្សាំខ្លួនបានល្អទៅនឹងជីវិតក្នុងបរិស្ថានដែលមានសារធាតុចិញ្ចឹមទាប។

The Top End ជាទីកន្លែងមួយក្នុងចំណោមទីកន្លែងដែលសំបូររុក្ខជាតិស៊ីសាច់ជាងគេបំផុតក្នុងលោកហើយភាពចំរុះរបស់វាមានកំរិតខ្ពស់បំផុតនៅលើជំរកទំនាបខ្សាច់នៅតំបន់ជនបទទីក្រុង ដាវីន។ យ៉ាងហោចណាស់ក៏មានសំណុំភាវៈរស់ស៊ីសាច់ចំនួន២៦ប្រភេទដែរនៅទីនេះ ជាពិសេសនៅតាមដងទន្លេ Howard River និង ទំនាបទឹកលិចតាមដងទន្លេ Adelaide River ។ ប្រភេទចំនួន៧ក្នុងចំណោមប្រភេទទាំងនេះត្រូវបានទទួលស្គាល់ក្រោមច្បាប់ដែនដីភាគខាងជើងថាជាប្រភេទ "ងាយរងគ្រោះថ្នាក់" ឬ "ជិតទទួលរងការគំរាមកំហែង"។

ប្រភេទរុក្ខជាតិផ្សេងទៀតក្នុងសហគមន៍រុក្ខជាតិលើកំរាលខ្សាច់ដែលកំពុងទទួលការគំរាមកំហែង រួមមានអ័រគីដេ និងតិណទសេ Typhonium taylori។

សហគមន៍រុក្ខជាតិលើកំរាលខ្សាច់

ការគំរាមកំហែង

ការកាប់ឆ្ការព្រៃដើម្បីទាញយកដី និងការរីកឡើងនៃកសិកម្មឬជនបទគឺជាបញ្ហាគ្រប់គ្រងដ៏សំខាន់បំផុតនាពេលបច្ចុប្បន្នដែលប៉ះពាល់តម្លៃអភិរក្សនៃសហគមន៍រុក្ខជាតិលើកំរាលខ្សាច់។

ភាពបែកខ្ញែកនៃរុក្ខជាតិ និងការប្រែប្រួលធារាសាស្ត្រទៅលើទឹកភ្លៀងដែលបានត្រូវយកក៏ទំនងជាធ្វើអោយប៉ះពាល់ដល់តំបន់ដីសើមនិងជំរកព្រៃរឹងទឹកភ្លៀងដែលងាយទទួលការរងគ្រោះ។

នៅពេលដែលការប្រើប្រាស់ដីឡើងកាន់តែខ្លាំងនៅក្បែរដាវីន កំណើននៃលំហូរសារធាតុចិញ្ចឹមពីតំបន់នៅក្បែរទំនងជាធ្វើអោយមានការប៉ះពាល់ប្រកបដោយគ្រោះថ្នាក់ទៅលើរុក្ខជាតិនិងសត្វដែលបានស៊ាំនឹងបរិស្ថានសហគមន៍រុក្ខជាតិលើកំរាលខ្សាច់ដែលមានសារធាតុចិញ្ចឹមទាប។

ការប្រើប្រាស់បរិស្ថានដែលងាយរងគ្រោះទាំងនេះមិនត្រឹមត្រូវសំរាប់ការកំសាន្តកំពុងតែចេញច្បាស់ឡើងពីព្រោះចំនួនប្រជាជនដាវីនបន្តកើនឡើង។នេះរាប់បញ្ចូលទាំងសកម្មភាពសត្វល្អិតបង្កភ្លើងឆេះ(firebug activity)ក្នុងតំបន់ដែលបណ្តាលអោយមានភ្លើងឆេះព្រៃដោយញឹកញាប់ក្នុងតំបន់មួយចំនួន។

ស្មៅប្លែកៗកំពុងតែរីករាលដាលកាន់តែខ្លាំងឡើង ហើយវាបានបង្កភ្លើងឆេះព្រៃកាន់តែក្តៅនិងបំផ្លាញកាន់តែខ្លាំង។ ការប្រើប្រាស់រថយន្តសំរាប់ការកំសាន្តក្នុងតំបន់ខ្សាច់ទាំងនេះបន្សល់ទុកនូវស្នាមខ្វងដែលធ្វើអោយប៉ះពាល់ដល់ធារាសាស្ត្រមូលដ្ឋាន។

ឯកសារយោងនិងឯកសារសំរាប់អានបន្ថែមទៀត

គោលការណ៍ណែនាំអំពីការកាប់ឆ្ការព្រៃ
nt.gov.au/property/land-clearing/apply-to-clear-freehold-land
កន្លែងអភិរក្សដែលមានសារៈសំខាន់
nt.gov.au/environment/environment-data-maps/important-biodiversity-conservation-sites/conservation-significance-list
ប្រភេទសត្វដែលទទួលរងការគំរាមកំហែង
denr.nt.gov.au/about/flora-and-fauna-division
គម្រោងផែនការរបស់ដែនដីភាគខាងជើងសហគមន៍រុក្ខជាតិលើកំរាលខ្សាច
nt.gov.au/property/building-and-development/northern-territory-planning-scheme

ព័ត៌មានបន្ថែម

Department of Environment
and Natural Resources
Rangelands Division
ទូរសព្ទ: 08 8999 3631
nt.gov.au/environment/soil-land-vegetation/native-vegetation
Rangelands Division
ទូរសព្ទ: 08 8995 5000
denr.nt.gov.au/about/flora-and-fauna-division

B. Stuckey
Calochilus caesius

I. Cowie
Utricularia holtzei

I. Cowie
Utricularia hamiltonii

តើយើងអាចធ្វើអ្វីបានដើម្បីអភិរក្សសហគមន៍រុក្ខជាតិលើកំរាលខ្សាច់?

ជាការប្រពៃសំរាប់ការភិរក្ស ការអភិវឌ្ឍគួរផ្លាត់ចេញពីតំបន់ដែលគេដឹងថាមានសំណុំការៈរស់កម្រនិងដែលទទួលរងការគំរាមកំហែងនៅទីនោះ។

- សំណើបអង្កេតការបង្កើតអោយមានកិច្ចព្រមព្រៀងអភិរក្សលើតំបន់ដីឯកជនដែលមានសហគមន៍រុក្ខជាតិលើកំរាលខ្សាច់ឬការបង្កើតអោយមានការរក្សាទុកតាមរូបភាពផ្សេងទៀត។

លោកអ្នកអាចចូលរួមចំណែកដោយ:

- ផ្សព្វផ្សាយអំពីសារៈសំខាន់តំបន់សហគមន៍រុក្ខជាតិលើកំរាលខ្សាច់។ វាងាយរងគ្រោះពីការរំខាន ហើយវាមានសំណុំការៈរស់ដែលកំពុងទទួលការគំរាមកំហែងផុតពូជ។
- ទប់ស្កាត់សកម្មភាពសត្វល្អិតបង្កភ្លើងឆេះនៅតំបន់ទាំងនោះ។កាត់បន្ថយភាពញឹកញាប់នៃ ភ្លើងឆេះព្រៃ។
- ការពារមិនអោយមានការរាលដាលស្មៅប្លែកៗជាពិសេសស្មៅមីហ្សិន(mission grasses) និងស្មៅហ្គែមបា (gamba grass) ទៅតំបន់ថ្មីៗក្នុងតំបន់ដាវីន។
- រៀបចំផែនការគ្រប់គ្រងស្មៅចង្រៃយ៉ាងសកម្មសំរាប់ដីរបស់លោកអ្នក។
- កាត់បន្ថយស្មៅប្លែកៗក្នុងតំបន់ដែលមានតម្លៃអភិរក្សខ្ពស់ដូចជា សហគមន៍រុក្ខជាតិលើ កំរាលខ្សាច់ហ្វ៉ាង ឬកន្លែងដែលភ្លើងឆេះព្រៃគំរាមកំហែងទ្រព្យសម្បត្តិ។
- រក្សាទុកដីដាំរុក្ខជាតិម្ចាស់ស្រុក តំបន់ទ្រនាប់ និងរបៀងក្នុងដីដំណាំច្បារ ជនបទ ផ្សិញ និងនៅខាងកើតដាវីន
- ហាមឃាត់មិនអោយមានសកម្មភាពកំសាន្តដូចជាការបើកឡានក្បាលឡេន និងការជិះម៉ូតូកង់កូឡាធំនៅតំបន់ងាយរងគ្រោះទាំងនេះ។